# គោលការណ៍ណែនាំអំពីមហោស្រពខ្សែភាពយន្តកុមារអន្តរជាតិអាស៊ី ឆ្នាំ២០២៣
# (ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា)

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣
ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## 1. ចំណុចសំខាន់

(1) មហោស្រពខ្សែភាពយន្តកុមារអន្តរជាតិអាស៊ី ឆ្នាំ២០២៣ នឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងមិណាមិ អាវ៉ាជិ ខេត្តហ្យូហ្គូ ប្រទេសជប៉ុន។

(2) ប្រធានបទនៃការប្រកួត "**អ្វីដែលខ្ញុំចង់បាន** (What I want)"

(3) សិស្សវិទ្យាល័យដែលនឹងចូលរួមមហោស្រពនេះមានមកពីប្រទេសជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានទាំង១០ប្រទេស និងប្រទេសទីម័រខាងកើត។

(4) រឿងខ្លីចំនួន៣រឿង នឹងត្រូវបានជ្រើសក្នុងការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា។

(5) សិស្សវិទ្យាល័យ៩នាក់(អាយុ១៥-១៨ឆ្នាំ សិស្ស៣នាក់ក្នុងមួយក្រុម ផលិតរឿងខ្លី) និងអ្នកដឹកនាំម្នាក់ (អាយុត្រឹម ឬក្រោម៤០ឆ្នាំ ដែលអាចប្រើប្រាស់ភាសាអង់គ្លេសបានយ៉ាងស្ទាត់ជំនាញ) នឹងត្រូវបានអញ្ជើញចូលរួមមហោស្រពនេះតាមរយៈកម្មវិធី JENESYS 2023 ASEAN-Japan Art Exchange។

## 2. លក្ខខណ្ឌសម្រាប់ការដាក់ពាក្យ

(1) សិស្សវិទ្យាល័យ៣នាក់(សញ្ជាតិខ្មែរ) ក្នុងមួយក្រុម (អាយុ ១៥-១៨ឆ្នាំ ថ្នាក់ទី១០ ឬ ទី១១ ក្នុងឆ្នាំសិក្សា២០២២-២០២៣)។

(2) សិស្សទាំងអស់ត្រូវមានកាតសិស្សឆ្នាំសិក្សា២០២២-២០២៣។

(3) ក្រុមនីមួយៗ អនុញ្ញាតឱ្យបង្កើតរឿងខ្លីតែមួយប៉ុណ្ណោះ ហើយគ្រប់ក្រុមទាំងអស់មិនអាចកែប្រែ ឬ ផ្លាស់ប្តូររឿងខ្លីបាន ទេ បន្ទាប់ពីបានប្រគល់រឿងខ្លីហើយ។

(4) រឿងខ្លីត្រូវថតដោយកាម៉េរ៉ាវីដេអូ ទូរសព្ទដៃ ឬ ថេបប្លេត។

(5) រឿងខ្លីត្រូវមានរយៈពេល**<u>តែ៣នាទីប៉ុណ្ណោះ</u>** (រឿងខ្លីលើសពី៣នាទីមិនត្រូវបានជ្រើសរើសទេ)។

(6) រឿងខ្លីដែលមិនទាន់បានបញ្ចាំងជាសាធារណៈ។

(7) សូមណែនាំឱ្យថតវីដេអូទំហំ ១៦:៩។

(8) ផលិតករត្រូវតែជាសិស្សវិទ្យាល័យ។ រាល់កិច្ចការផលិតរឿងខ្លី ត្រូវតែធ្វើឡើងដោយសាម៉ីខ្លួន មិនអនុញ្ញាតឱ្យអ្នកដែលមិនមែនជាសមាជិកក្រុមសហការផលិតទេ។

(9) ផលិតករមិនត្រូវប្រើកុំព្យូទ័រក្រាហ្វិក(CG)ទេ។

(10) ផលិតករមិនគួរប្រើប្រាស់ អក្សរ ការអត្ថាធិប្បាយ ឬ ចំណងជើងរងច្រើនពេកទេ នៅក្នុងរឿងខ្លី។

(11) ករណីដែលផលិតករប្រើប្រាស់ឯកសារណា(ចម្រៀង ភ្លេង ឬ រូបភាព) ដែលមានកម្មសិទ្ធិបញ្ញា ត្រូវទាក់ទងជាមួយអ្នកមានកម្មសិទ្ធបញ្ញានោះ ដើម្បីទទួលការយល់ព្រមឱ្យប្រើប្រាស់ត្រឹមត្រូវ។

## 3. លក្ខខណ្ឌមិនអាចដាក់ពាក្យចូលរួម

(1) បេក្ខជនដែលធ្លាប់បានទៅប្រទេសជប៉ុន។

(2) បេក្ខជនដែលមានសញ្ជាតិជប៉ុន។

## 4. លក្ខខណ្ឌវិនិច្ឆ័យ

(1) គណៈមេប្រយោគនឹងវិនិច្ឆ័យទៅលើ"សារសំខាន់ដែលទទួលបានពីរឿង"ជាចម្បង។

(2) គណៈមេប្រយោគក៏វិនិច្ឆ័យលើ "សាច់រឿង" "បច្ចេកទេស" និង "ការសម្តែង (តួអង្គប្រុស ស្រី)"ដែរ។

(3) មហោស្រពនេះមានគោលបំណងផ្តល់ឱកាសមួយសម្រាប់សិស្សស្វែងយល់ពីកិច្ចការផ្សេងៗ ដូចជាការងារជាក្រុម ការដឹងអំពីការទទួលខុសត្រូវជាដើម ហើយក៏ដូចជាដើម្បីសម្រេចបាននូវការរីកចម្រើនផ្លូវចិត្តតាមរយៈការផលិតខ្សែភាពយន្តផងដែរ។ សូមបញ្ជាក់ថា មហោស្រពនេះ មិនមានគោលបំណងបណ្តុះបណ្តាលសិស្សឱ្យក្លាយជាផលិតករផលិតភាពយន្តអាជីពនោះទេ។ ដូច្នេះគណៈមេប្រយោគនឹងវាយតម្លៃភាពយន្តដែលឆ្លុះបញ្ចាំងពីប្រធានបទ និងចិត្តគំនិតរបស់ផលិតករ ព្រមទាំងសាច់រឿង ដែលជះឥទ្ធិពលប្រសើរដល់សង្គម ទោះបីជាផលិតករមិនមានជំនាញក្នុងការផលិតរឿងក៏ដោយ។

## 5. គម្រោងកម្មវិធី

| កាលបរិច្ឆេទ | កម្មវិធី | ទីកន្លែង |
|---|---|---|
| ថ្ងៃចន្ទ ទី១៤ ខែសីហា | បើកទទួលពាក្យ | ស្ថានទូតជប៉ុនប្រចាំកម្ពុជា |
| ថ្ងៃអាទិត្យ ទី២០ ខែសីហា ម៉ោង ២រសៀល | បទបង្ហាញណែនាំចូលរួមប្រកួតផលិតរឿងខ្លីសម្រាប់សិស្សវិទ្យាល័យ | បន្ទប់លេខ៩ នៃ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ឬ តាមZoom |
| ថ្ងៃព្រហស្បតិ៍ ទី២១ ខែកញ្ញា ត្រឹមម៉ោង៤:៣០ល្ងាច | ផុតកំណត់ការទទួលពាក្យ និងទទួលរឿងខ្លី | ស្ថានទូតជប៉ុនប្រចាំកម្ពុជា |
| ថ្ងៃទី២២ ដល់២៨ ខែកញ្ញា | សម្រេចលទ្ធផលវគ្គជម្រុះ | ដោយស្ថានទូតជប៉ុន (ក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យបញ្ជាក់ពីចំណុចអវិជ្ជមាន) |
| ថ្ងៃចន្ទ ទី២ ខែតុលា | ប្រកាសលទ្ធផលវគ្គជម្រុះ | ផ្សព្វផ្សាយនៅលើគេហទំព័រ និងហ្វេសប៊ុក ស្ថានទូតជប៉ុន |
| ថ្ងៃចន្ទ ទី៩ ខែតុលា ម៉ោង ២រសៀល | ការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា | មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) |
| ថ្ងៃពុធ ទី១៣ ដល់ ថ្ងៃអង្គារ ទី១៩ ខែធ្នូ | ទស្សនកិច្ចនៅប្រទេសជប៉ុន និងចូលរួមមហោស្រពភាពយន្តកុមារអន្តរជាតិតាមរយៈកម្មវិធីJENESYS 2023 | ខេត្តហ្វូហ្គូ ប្រទេសជប៉ុន |
| ថ្ងៃសៅរ៍ ទី១៦ ខែធ្នូ ម៉ោង១រសៀល | មហោស្រពខ្សែភាពយន្តកុមារអន្តរជាតិអាស៊ី ឆ្នាំ២០២៣ | ទីក្រុងមិណាមិ អាវ៉ាជិ ខេត្តហ្យូហ្គូ ប្រទេសជប៉ុន |

*រក្សាសិទ្ធក្នុងការកែប្រែកម្មវិធី។

6. ការប្រកាសផ្សព្វផ្សាយ

(1) ស្ថានទូតជប៉ុនប្រកាសផ្សព្វផ្សាយគោលការណ៍ណែនាំការប្រកួតនេះ នៅលើគេហទំព័រ និង ហ្វេសប៊ុកស្ថានទូតជប៉ុន។

(2) ក្រសួងអប់រំក៏ចូលរួមប្រកាសផ្សព្វផ្សាយគោលការណ៍ណែនាំការប្រកួតនេះ ទៅដល់សិស្សវិទ្យាល័យទូទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។

7. ការដាក់ពាក្យ និងការជម្រុះ

(1) បេក្ខជនតម្រូវឱ្យដាក់ពាក្យចូលរួម និងប្រគល់ខ្សែភាពយន្ត តាមរយៈ Microsoft form (https://forms.office.com/r/6UAWJhLNKm) ត្រឹម ម៉ោង៤:៣០រសៀល ថ្ងៃព្រហស្បតិ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២៣។ បេក្ខជនចាំបាច់ត្រូវបង្ហាញកាតសិស្ស នៅពេលត្រូវបានជ្រើសរើសចូលរួមប្រកួតវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត នៅCJCC។

   a. ខ្សែភាពយន្តរយៈពេល៣នាទី (សូមបញ្ចូលរឿងរបស់អ្នកទៅក្នុង Google drive ដោយចុចយកពាក្យថា sharable link ឬ Linkផ្សេងដែលអាចផ្ទុករឿងរបស់អ្នកបាន បំពេញLink ក្នុង Microsoft form តាមរយៈការបំពេញពាក្យរបស់អ្នក)

   b. កាតសិស្ស (សូមថតចម្លងកាតសិស្សភ្ជាប់មកជាមួយពេលបំពេញពាក្យ Microsoft form ដោយវិធីសាស្រ្តដូចដាក់ខ្សែភាពយន្តរបស់អ្នកខាងលើ)

(2) បេក្ខជនដែលបានដាក់ពាក្យហើយ ឬ មិនទាន់ដាក់ពាក្យ សូមចូលរួមស្ដាប់បទបង្ហាញណែនាំអំពីការចូលរួមប្រកួតផលិតរឿងខ្លីសម្រាប់សិស្សវិទ្យាល័យ(ដោយផ្ទាល់ ឬ តាមZoom) នៅថ្ងៃអាទិត្យ ទី២០ ខែសីហា វេលាម៉ោង២រសៀលដល់៣រសៀលនៅCJCCបន្ទប់លេខ៩ដោយចុះឈ្មោះជាមុនតាមលីងនេះ (https://forms.office.com/r/HcJdxhikbQ)។

(3) បន្ទាប់ពីថ្ងៃផុតកំណត់ថ្ងៃដាក់ពាក្យហើយ ស្ថានទូតសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជ្រើសរើសខ្សែភាពយន្តចំនួន១៥រឿងចូលរួមប្រកួតវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រ។

8. ការប្រកួតវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា

(1) ស្ថានទូតជប៉ុននឹងអញ្ជើញតំណាងក្រសួងអប់រំយុវជន និងកីឡា ក្រសួងព័ត៌មាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាគណៈមេប្រយោគ។

(2) ស្ថានទូតជប៉ុននឹងអញ្ជើញគណៈមេប្រយោគផ្សេងៗទៀតពីស្ថាប័នឯកជន។

(3) បន្ទាប់ពីចាក់បញ្ចាំងរឿងខ្លីទាំង១៥រឿងហើយ គណៈមេប្រយោគ នឹងជ្រើសរើស៣រឿងដើម្បីចូលរួមការប្រកួតវគ្គផ្ដាច់ព្រ័ត្រនៅប្រទេសជប៉ុន។

9. ការប្រកួតវគ្គផ្ដាច់ព្រ័ត្រនៅប្រទេសជប៉ុន

(1) សិស្សវិទ្យាល័យ៩នាក់ និងអ្នកដឹកនាំម្នាក់ នឹងត្រូវបានអញ្ជើញចូលរួមការប្រកួតវគ្គផ្ដាច់ព្រ័ត្រក្នុងមហោស្រពនេះតាមរយៈកម្មវិធី JENESYS 2023 ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣។

(2) ក្រោយពីបញ្ចប់ការប្រកួតវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា សិស្សវិទ្យាល័យ៩នាក់ និងអ្នកដឹកនាំម្នាក់ ត្រូវដាក់ឯកសារសម្រាប់ចូលរួមកម្មវិធី JENESYS 2023 និងឯកសារលិខិតឆ្លងដែនតាមកាលកំណត់របស់ស្ថានទូត

ជប៉ុន ។

(3) រឿងខ្លីដែលបានជ្រើសរើសក្នុងការប្រកួតវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនៅប្រទេសកម្ពុជាត្រូវបានយកទៅចូលរួមប្រកួតនៅប្រទេសជប៉ុន ទោះបីផលិតករនោះមិនអាចចូលរួមកម្មវិធីដូចលក្ខន្តិកៈដែលបានរៀបរាប់ខាងលើ។

(4) រដ្ឋាភិបាលជប៉ុនមិនអនុញ្ញាតចំពោះបុគ្គលដែលមិនត្រូវបានអញ្ជើញឱ្យចូលរួមកម្មវិធី JENESYS 2023 ទៅចូលរួមការប្រកួតវគ្គផ្តាច់ព្រ័ត្រនៅប្រទេសជប៉ុនទេ។ បុគ្គលទាំងនោះ រួមមានទាំងក្រុមគ្រួសារ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិរបស់បេក្ខជនប្រកួត ទោះបីជារាល់ការចំណាយធ្វើដោយខ្លួនឯងក៏ដោយ។

## 10. លក្ខន្តិកៈទូទៅនៃកម្មវិធី JENESYS 2023

(1) បេក្ខជនត្រូវយល់ដឹងឱ្យបានច្បាស់ពីគោលបំណងនៃកម្មវិធី JENESYS 2023 ។

(2) បេក្ខជននឹងត្រូវបានជ្រើសរើសជាអ្នកបានបំពេញការងារបានល្អក្នុង "មហោស្រពខ្សែភាពយន្តកុមារអន្តរជាតិអាស៊ីលើកទី១៦" នៅប្រទេសជប៉ុន។

(3) ត្រូវមានសុខភាពល្អ។ *

*ចំពោះបេក្ខជនដែលមានជំងឺ នឹងទទួលការអនុញ្ញាតចូលរួមកម្មវិធី លុះត្រាតែមានលិខិតបញ្ជាក់ពីពេទ្យថាអាចចូលរួមកម្មវិធីនេះបាន។ ចំពោះអ្នកកំពុងមានផ្ទៃពោះមិនអាចចូលរួមកម្មវិធីនេះបានទេ។

(4) បេក្ខជនត្រូវមានឆន្ទៈក្នុងការចែករំលែក និងផ្សព្វផ្សាយព័ត៌មានអំពីប្រទេសជប៉ុន និងបទពិសោធន៍នៃកម្មវិធីតាមរយៈប្រព័ន្ធបណ្តាញសង្គម (SNS) ជាដើម ព្រមទាំងតាមគណនីហ្វេសប៊ុកផ្ទាល់ខ្លួនដោយចែករំលែកឱ្យបានសកម្ម។

(5) គោលបំណងនៃកម្មវិធី

កម្មវិធី JENESYS 2023 ជាកម្មវិធីផ្លាស់ប្តូររវាងប្រជាជន និងប្រជាជនក្នុងប្រទេសជប៉ុន និងតំបន់អាស៊ី-ប៉ាស៊ីហ្វិកដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលជប៉ុន។ កម្មវិធីនេះមានគោលបំណងជំរុញការយល់ដឹង និងទំនុកចិត្តទៅវិញទៅមក ក្នុងចំណោមប្រជាជនជប៉ុន និងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ កម្មវិធីនេះ ក៏លើកទឹកចិត្ត និងការយល់ដឹង និងការផ្សព្វផ្សាយអំពីសេដ្ឋកិច្ចសង្គម ប្រវត្តិសាស្ត្រ វប្បធម៌ចម្រុះ នយោបាយ និងទំនាក់ទំនងការទូតផងដែរ។

ពាក្យពេញនៃ JENESYS គឺ Japan-Est Asia Network of Exchange for Students and Youths ។

## 11. សម្រាប់ព័ត៌មានលម្អិត

សូមទាក់ទងមកផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុនប្រចាំកម្ពុជា។

លេខទំនាក់ទំនង៖ ០២៣-២១៧-១៦១ លេខភ្ជាប់បន្ត ១១២២

អាស័យដ្ឋានអ៊ីម៉ែល៖ info.jpn@pp.mofa.go.jp